


# ច្បាប់ដ៏សំខាន់ក្នុងការ ការពារអ្នកប្តូរភេទដែលប្រឈមនឹងបញ្ហានៅក្នុងរដ្ឋម៉ាសាឈូសេត

នៅខែវិច្ឆិកាឆ្នាំ ២០១៨ អ្នកបោះឆ្នោតទាំងអស់នៅរដ្ឋម៉ាសាឈូសេតនឹងត្រូវបានគេសួរនៅប្រអប់ឆ្នោតស្តីពីការបោះឆ្នោតគាំទ្រលើច្បាប់លេខ៣ ក្នុងការពារអ្នកប្តូរភេទពីការរើសអើងនៅតាមទីសារធារណៈ ដូចជា នៅតាមភោជនីយដ្ឋាន ហាងទំនិញ និងនៅមន្ទីរពេទ្យ។

## យើងមកដល់ទីនេះដោយរបៀបណា?

កាលពីឆ្នាំ២០១៦ អង្គការសេរីភាពសម្រាប់ប្រជាជន នៃរដ្ឋម៉ាសាឈូសេតទាំងអស់ (Freedom for All Massachusetts) បានតស៊ូមតិអោយមានការដាក់បញ្ចូលការការពារអ្នកប្តូរភេទនៅតាមទីសារធារណៈ បន្ថែមពីលើច្បាប់ស្តីពីការគ្មានការរើសអើងរបស់រដ្ឋម៉ាសាឈូសេត។ លោកអភិបាល Baker បានចុះហត្ថលេខាដាក់ ច្បាប់នេះចូលជាធរមាននៅខែកក្កដា ឆ្នាំ ២០១៦។

បន្តិចក្រោយមក ក្រុមអ្នកប្រឆាំងនៃច្បាប់នេះបាននាំគ្នាប្រមូលហត្ថលេខាមួយចំនួនដើម្បីនាំអោយមានការលុបចោលនៃច្បាប់នេះ តាមរយៈការបោះឆ្នោតនៅឆ្នាំ ២០១៨។

ជ័យជំនះដែលយើងបានព្យាយាមប្រឹងប្រែងយ៉ាងលំបាកសម្រាប់ច្បាប់នេះកំពុងតែជួបបញ្ហាប្រឈម។

## យើងធ្វើអ្វីបន្ទាប់ទៀត?

អង្គការសេរីភាពសម្រាប់ប្រជាជននៃរដ្ឋម៉ាសាឈូសេតទាំងអស់ (Freedom for All Massachusetts) បានធ្វើការយ៉ាងស្វិតស្វាញដើម្បីប្រឆាំងជាមួយនឹងការព្យាយាមលុបបំបាត់ច្បាប់នេះ ដែលវាធ្វើឡើងដោយការរើសអើង និងប្រកបដោយគ្រោះថ្នាក់។

នេះជាយុទ្ធនាការមួយដែលយើងមិនអាចចាញ់បាន។ ប្រសិនបើរដ្ឋម៉ាសាឈូសេតលុបបំបាត់ការ ការពារអ្នក ប្តូរភេទនេះ វានឹងនាំអោយមានផលប៉ះពាល់យ៉ាងខ្លាំងដល់ជីវិតអ្នកដែលនៅក្នុងផ្ទះ ក៏ដូចជាក្រុមគ្រួសារ សហគមន៍ រួមទាំងសេដ្ឋកិច្ចរបស់រដ្ឋទាំងមូលផងដែរ។

វាក៏បង្កជាគំរូដ៏គ្រោះថ្នាក់មួយ ដែលធ្វើអោយយើងក្លាយជារដ្ឋដំបូងបំផុតនៃទូទាំងប្រទេស ដែលបានផាត់ចេញនូវសិទ្ធិរបស់អ្នកប្តូរភេទតាមរយៈការបោះឆ្នោត។

## អ្វីដែលគួររំពឹងទុក

ក្រុមប្រឆាំងនៃច្បាប់នេះដែល ជាក្រុមតែមួយដែលជំទាស់នឹងសិទ្ធិរៀបការរបស់អ្នកស្រលាញ់ភេទដូចគ្នានឹងបន្តប្រើភាពភ័យខ្លាច និងការផ្តល់ព័ត៏មានមិនពិតដើម្បីបន្តការមិនគាំទ្ររបស់ពួកគេ។

យើងកំពុងតែធ្វើគ្រប់វិធីដើម្បីអប់រំដល់សាធារណៈជនដែលមានសិទ្ធិបោះឆ្នោតថា វាគ្មានភស្តុតាងណាដែលបញ្ជាក់ថាច្បាប់នេះនឹងធ្វើអោយស្រ្តី និងកុមារគ្មានសុវត្ថិភាពទេ។ អ្នកតស៊ូមតិស្តីពីសុវត្ថិភាព រួមមានកម្លាំងមានសមត្ថកិច្ច និងថ្នាក់ដឹកនាំរបស់អង្គការដែលប្រឆាំង នឹងការបំពានផ្លូវភេទក៏បានយល់ព្រម។ ចាប់តាំងពីច្បាប់នេះចូលជាធរមានមក មិនមានមនុស្សបំពានច្បាប់នេះនោះទេ។ លើសពីនេះទៅទៀតទីក្រុងជាច្រើនរួមទាំងក្រុងបូស្តុន (Boston) មានការការពារទាំងនេះជាជាងមួយទស្សវត្តទៅហើយ។

# សូមបោះឆ្នោតយល់ព្រមលើច្បាប់លេខ ៣ នាខែវិច្ឆិកានេះ

ដើម្បីរក្សាភាពថ្លៃថ្នូរ និងការគោរពដល់អ្នកប្តូរភេទដែលជាអ្នករស់នៅជិតយើងនៅក្នុងរដ្ឋម៉ាសាឈូសេត

សមាគមន៍ និងភ្នាក់ងារសំខាន់ៗនៃក្រុមកម្លាំងមានសមត្ថកិច្ចរបស់រដ្ឋ ក្រុមអ្នកតស៊ូមតិតដល់ជនរងគ្រោះ និងស្រ្តីថ្នាក់ជាតិ និយោជកដ៏សំខាន់ ក្រុមកីឡាករជើងឯក និងអ្នកដឹកនាំសាសនាផ្សេងៗ រួមគ្នាគាំទ្រការ ការពារសិទ្ធិស្មើគ្នា ដល់អ្នកប្តូរភេទដែលជា អ្នករស់នៅជិតខាង ក្រុមគ្រួសារ  និងមិត្តភក្តិរបស់យើង។

www.freedommassachusetts.org

freedom for all MASSACHUSETTS | YES ON 3

# អ្វីទៅជាគ្រឹស្ថានសាធារណៈ?

នៅឆ្នាំ២០១៦ រដ្ឋម៉ាសាឈូសេតបានអនុម័តច្បាប់ការពារ ការរើសអើងដល់អ្នកប្តូរភេទដែលជាមិត្តភក្តិ គ្រួសារ និងអ្នកជិតខាងរបស់យើងនៅតាម ទីសាធារណៈ ដែលវាសំដៅលើទីកន្លែងទាំងឡាយណា ក្រៅពីផ្ទះ កន្លែងធ្វើការ ឬសាលារៀន។ ដែលទាំងនេះរួមមានទីកន្លែងដូចជា៖

ផ្សារទំនិញ | ភោជនីយដ្ឋាន | សណ្ឋាគារ | មន្ទីរពេទ្យ | សួនសាធារណៈ | រោងកុន | មធ្យោបាយធ្វើដំណើរសាធារណៈ

ប្រជាជននៃរដ្ឋម៉ាសាឈូសេតគាំទ្រការ ការពារសិទ្ធិស្មើគ្នាដល់អ្នកប្តូរភេទដែលជា អ្នករស់នៅជិតខាងយើង ក្រុមគ្រួសារ និងមិត្តភក្តិរបស់យើងដូចមានចែងក្រោមច្បាប់នេះ។

## ការធ្វើប្រជាមតិលើច្បាប់ដែលមានស្រាប់៖ ច្បាប់ដែលពាក់ព័ន្ធ

# ការមិនរើសអើងចំពោះអ្នកប្តូរភេទ

បោះឆ្នោតយល់ព្រម (YES VOTE) នឹងទុកច្បាប់អោយនៅដដែល ដែលច្បាប់នេះទប់ស្កាត់ការរើសអើងលើអត្តសញ្ញាណយេនឌ័រ នៅតាមទីសារធារណៈ

បោះឆ្នោតថា ទេ (NO VOTE) នឹងលុបចោលច្បាប់ស្តីពីការមិនរើសអើងនេះ